# សាមគ្គីភាព

តើ សាមគ្គីភាព វា ជា ធម្មជាតិ នៃ សត្វលោក ? បើ យើង សង្កេតមើល ការរស់នៅ នៅក្នុង សហគមន៍ ឬ ហ្វូង នៃ ស្រមោច ក្តី ឃ្មុំ ក្តី ស្វា ក្តី យើង ឃើញមាន សាមគ្គីភាព ជា មូលដ្ឋាន នៅក្នុង សហគមន៍។ សាមគ្គីភាព នោះ វា ពុំមែន ជា បែបបទ នៃ ការគិត តែ ជា ទំលាប់ ជា ធម្មជាតិ ដើម្បី ការរស់រានជីវិត របស់សហគមន៍។ សាមគ្គីភាព ក៏មានដែរ នៅក្នុង សង្គមដើម នៃ មនុស្សលោក ព្រោះ មនុស្សលោក ក៏ជា សត្វលោក។ សាមគ្គីភាព នោះឯង ដែល ជា បែបបទ នៃ កុសល និង អកុសល ដោយគ្មានគិត ព្រោះ វា ជា ធម្មជាតិ សំរាប់ ការរស់រានជីវិត គឺ ថា អ្វី ដែល មាន ប្រយោជន៍ ជា កុសល អ្វី ដែល ជា ចង្រៃ ជា អកុសល សំរាប់ សហគមន៍ ឬ សង្គម។ ជំនឿ សាសនាក្តី និង ប្រភព ច្បាប់ ក្តី សុទ្ធតែ កើតចេញ ពី ការសង្កេត លើ ធម្មជាតិ ហើយ យកមក កែឆ្នៃ ដើម្បី ស្ថាបនា ជំនឿគ្រឹះ នៃ សាសនា និង ច្បាប់ នានា នៃ សង្គម សំរាប់ ដាក់អោយមាន សីលធម៌ និង សណ្តាប់ធ្នាប់ នៅក្នុង នរៈសង្គម។ សីលធម៌ និង សណ្តាប់ធ្នាប់ នេះឯង អាច ចាត់ទុក ជា និស្សន្ទវត្ថុ (dérivée) នៃ សាមគ្គីភាព ជា ធម្មជាតិ នោះឯង។ នៅ ស្រុកខ្មែរ សព្វថ្ងៃ ដែល ប្រជាជន កំពុង ប្រឈរមុខនឹង ជម្ងឺ កូវីដ ១៩ គេ ឃើញ ថា របប ក្រុងភ្នំពេញ ប្រើ សម្តី សាមគ្គីភាព តែ នៅក្នុង គំនិត អកុសល គឺ យកមក ធ្វើ នយោបាយ សំរាប់ ការពារ អំណាច របស់ខ្លួន តែ ប៉ុណ្ណោះ។

ឧប សៅ សទ្ធា គំនិត ៦ មេសា ២០២០